-យល់ឃើញថា : លទ្ធផលនៃការបោះឆ្នោត នៅឃុំអញ្ចើម ត្រូវបានទទួលស្គាល់និងយល់ព្រមចុះហត្ថលេខា ពីតំណាងគណបក្សហ្វ៊ុនស៊ិនប៉ិច ឈ្មោះ **គីម ម៉េងហ៊ួរ** រួចគប់គ្រប់គ្រាន់ហើយ ដូច្នេះបណ្ដឹង តវ៉ា របស់គណបក្សហ្វ៊ុនស៊ិនប៉ិច នឹងត្រូវអស់ន័យទៀតហើយ ។

-យល់ឃើញថា : ពាក្យបណ្ដឹងនេះគ្មានទឡ្ហីករណ៍គ្រប់គ្រាន់ ដើម្បីបើកសវនាការតាមមាត្រា១១៧ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដើម្បីក្រុមប្រឹក្សាធម្មនុញ្ញសំរេចបដិសេធពុំទទួលពាក្យបណ្ដឹងតវ៉ានេះ ។

-យល់ឃើញថា : សេចក្ដីសំរេចលេខ ០៨-១៦០៨/៩៨ គជប ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ១៩៩៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវ ទន្ទឹមនេះគប្បីបញ្ជាក់ថា " មានតំណាងគណបក្សហ្វ៊ុនស៊ិនប៉ិច មួយរូបឈ្មោះ **គីម ម៉េងហ៊ួរ** បានចុះហត្ថលេខាទទួលស្គាល់លទ្ធផលរួម នៃការបោះឆ្នោត នៅឃុំអញ្ចើម ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

**សំរេច**

១-បដិសេធពាក្យបណ្ដឹងជំទាស់ លេខ ១៦២/៩៨ នគក ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណបក្សហ្វ៊ុនស៊ិនប៉ិច ដែលទាក់ទងនឹងសេចក្ដីសំរេច លេខ០៨-១៦០៨/៩៨ គជប ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

២-តម្កល់សេចក្ដីសំរេច លេខ ០៨-១៦០៨/៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ដោយត្រូវបន្ថែមបញ្ជាក់អោយច្បាស់ថា "តំណាងឈ្មោះ **គីម ម៉េងហ៊ួរ** បានចុះហត្ថលេខាទទួលស្គាល់លទ្ធផលបោះឆ្នោតនៅឃុំអញ្ចើម រួចហើយ ។"

៣-សេចក្ដីសំរេចនេះធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៨ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសំរេចស្ថាពរបិទផ្លូវតវ៉ា ។

| | |
|---|---|
| ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ | ដកស្រង់ត្រឹមត្រូវតាមច្បាប់ដើម |
| ហត្ថលេខា និងត្រា | លេខាធិការ |
| **ចាន់ សុក** | **ម៉េង គីមលី** |

★★★

ភ្នំពេញ,ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨

## សេចក្ដីសំរេច លេខ ១៩ កបធ/សសរ

***

## ក្រុមប្រឹក្សាធម្មនុញ្ញ

-យល់ឃើញថា : ពាក្យបណ្ដឹងលេខ១៦២/៩៨ នគក របស់គណបក្សហ្វ៊ុនស៊ិនប៉ិច ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៨ ជំទាស់នឹងសេចក្ដីសំរេច របស់គណៈកម្មាធិការជាតិរៀបចំការបោះ

ឆ្នោត លេខ០៨/១៦៩០/៩៨ គជប ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ១៩៩៨ ស្តីពីការបញ្ឈប់ការរាប់សន្លឹកឆ្នោតឡើងវិញនៅទូទាំងប្រទេស ជាបណ្តឹងមិនត្រឹមត្រូវទេ ។

-យល់ឃើញថា : ពេលប្រមូលលទ្ធផលទូទាំងប្រទេសមកពិនិត្យ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានទទួលពាក្យបណ្តឹងរបស់គណបក្សហ្វ៊ុនស៊ិនប៉ិច ស្តីពីភាពមិនប្រក្រតីនៅតាមបណ្តុំមណ្ឌលបោះឆ្នោត ។

-យល់ឃើញថា : ពាក្យបណ្តឹងរបស់គណបក្សហ្វ៊ុនស៊ិនប៉ិច ភាគច្រើនលើសលប់មិនបានធ្វើតាមលំដាប់ពីការិយាល័យរៀបចំការបោះឆ្នោត មកគណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោត គណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោត គណៈកម្មការជាតិរៀបចំការបោះឆ្នោត ។

-យល់ឃើញថា : របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានគុណសម្បត្តិខ្ពស់ក្នុងការដោះស្រាយពាក្យបណ្តឹង ដោយបានតាំងគណៈកម្មការ ADHOC មួយ នៅថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ១៩៩៨ និងបានអនុម័តនីតិវិធីនៃការរាប់សន្លឹកឆ្នោតឡើងវិញ នាថ្ងៃទី០៣ ខែសីហា ឆ្នាំ ១៩៩៨ ។

-យល់ឃើញថា : គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានផ្តល់សិទ្ធិដល់ គណបក្សហ្វ៊ុនស៊ិនប៉ិច ជាអ្នកចង្អុលគំរូ ( Echantillon, sampling ) ឃុំ ដែលត្រូវរាប់ឡើងវិញ ដោយរើសយកឃុំណា ដែលគេយល់ថាមានភាពមិនប្រក្រតីធ្ងន់ធ្ងរជាងគេ ដើម្បីយកមកអោយគណៈកម្មការ (ADHOC) ផ្ទៀងផ្ទាត់ និងរាប់ឡើងវិញ ។

-យល់ឃើញថា : ពេលផ្ទៀងផ្ទាត់ និងរាប់ឡើងវិញសនៅឃុំ ០៨ (ប្រាំបី) លទ្ធផលទទួលបានមានគម្លាត ០,៦២% ទៅ ២,១៩% ពីលទ្ធផលបណ្តោះអាសន្នដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានប្រកាសតែប៉ុណ្ណោះ ។

--យល់ឃើញថា : ពេលផ្ទៀងផ្ទាត់ និង រាប់សន្លឹកឆ្នោតឡើងវិញ គណៈកម្មការ ADHOC បានអនុញ្ញាតអោយអ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងភ្នាក់ងារគណបក្សនយោបាយបានចូលរួម ។

-យល់ឃើញថា : គ្រប់កំណត់ហេតុនៃការផ្ទៀងផ្ទាត់ និង រាប់សន្លឹកឆ្នោតឡើងវិញ នៅ ០៨ (ប្រាំបី ) ឃុំ សុទ្ធតែមានការចុះហត្ថលេខាទទួលស្គាល់ពីភ្នាក់ងារគណបក្ស ក្នុងនោះមានភ្នាក់ងារគណបក្សហ្វ៊ុនស៊ិនប៉ិច ផងដែរ ។

-យល់ឃើញថា : ក្រោយពីបានស្តាប់របាយការណ៍របស់គណៈកម្មការ ADHOC អំពីលទ្ធផលនៃការផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតឡើងវិញថា មានគម្លាតមធ្យម ០,៣% ពីលទ្ធផលបណ្តោះអាសន្ន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានសន្និដ្ឋានថា លទ្ធផលនេះមិនជះឥទ្ធិពលដល់អាសនៈរបស់គណបក្សឡើយ ហើយបានសំរេចបញ្ឈប់ការរាប់សន្លឹកឆ្នោតឡើងវិញ ។

-យល់ឃើញថា : សេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ០៨/១៦៩០/៩៨ គជប ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ មានលក្ខណៈត្រឹមត្រូវ ។

**សំរេច**

ចំពោះមុខតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

កំបាំងមុខតំណាងគណបក្សហ្វ៊ុនស៊ិនប៉ិច ប៉ុន្តែបានកោះហៅជាចំពោះមុខ

១-ការលើកឡើងពាក្យបណ្តឹងជំទាស់ ១៦២/៩៨ ឧតក របស់គណបក្សហ្វ៊ុនស៊ិនប៉ិច ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ ជំទាស់នឹងសេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ០៨-១៦៩០/៩៨ គជប ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ ស្តីពីការបញ្ឈប់ការរាប់សន្លឹកឆ្នោតឡើងវិញនៅទូទាំងប្រទេស ។

២-តម្កល់សេចក្តីសំរេច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០៨-១៦៩០/៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ ទុកជាបានការពេញលេញ ។

៣-សេចក្តីសំរេចនេះធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៨ ក្នុងសវនាការជាសាធារណៈ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរប្រើផ្លូវពុំបាន ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ — ចំលងត្រឹមត្រូវតាមច្បាប់ដើម

ហត្ថលេខា និងត្រា — លេខាធិការ

**ចាន់ សុក** — **ម៉េន គីមលី**

★★★

ភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៨

**សេចក្តីសំរេច លេខ ២០ កបធសស**

***

**ក្រុមប្រឹក្សាធម្មនុញ្ញ**

-យល់ឃើញថា : ពាក្យបណ្តឹងលេខ១០១/៩៨ គសរ/ច របស់គណបក្សសម រង្ស៊ី ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៨ ជំទាស់នឹងសេចក្តីសំរេច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ០៨/១៦៩០/៩៨ គជប ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ១៩៩៨ ស្តីពីការបញ្ឈប់ការរាប់សន្លឹកឆ្នោតឡើងវិញនៅទូទាំងប្រទេស ជាបណ្តឹងមិនត្រឹមត្រូវទេ ។

-យល់ឃើញថា : ពេលប្រមូលលទ្ធផលទូទាំងប្រទេសមកពិនិត្យ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានទទួលពាក្យបណ្តឹងរបស់គណៈបក្សសម រង្ស៊ី ស្តីពីភាពមិនប្រក្រតីនៅតាមមណ្ឌលបោះឆ្នោត ។

-យល់ឃើញថា ពាក្យបណ្តឹងរបស់គណៈបក្សសម រង្ស៊ី ភាគច្រើនលើសលប់មិនបានធ្វើតាមលំដាប់ពីការិយាល័យរៀបចំការបោះឆ្នោត មកគណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោត គណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោត គណៈកម្មការជាតិរៀបចំការបោះឆ្នោត ។